...បនា និងអក្សរសាស្ត្រ ...បោះពុម្ពផ្សាយ

អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្វូងនិពទ្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកជំណឿសាសនាៈ ព្រះទេពសត្ថា សូរ - ហៈយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័...|
|---|---|---|
| ហ្វូងនិពទ្ធមន្ត្រី ញ៉ុក - ថែម | ពាក្យថ្មីៗ ក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ....... | ២៤៤ |
| — | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក).. | ២៥៥ |
| អ្នកឧកញ៉ា ឈឹម - ក្រសេម | ព្រះរាជពង្សាវតារភាគទី ១ សម័យនគរភ្នំ (តមក). | ២៦២ |
| លោក វ៉ាយ - ប៊ុត ក្រមការ | សុភាសិតខ្មែរ ភាគទី ១ (តមក) ........... | ២៧១ |
| — | ប្រជុំពាក្យព្រេងនិងបាវចនាបារាំង (តមក)..... | ២៧៥ |
| លោកអាចារ្យ និញ - ប្រាជ្ញ | រឿងធ្វើស្រែខ្មែរ នៅកម្ពុជាក្រោម (កូស័ងស៊ីន) (តមក - ចប់) ........................ | ២៧៩ |
| អ្នកឧកញ៉ាព្រះឃ្លាំង ឆង | រឿងរះភាគកុលកុមារ (តមក) ............. | ២៨៦ |
| **ផ្នែកសាសនា** | | |
| ព្រះសពមហារស់ - កោ | សាបត្តិកថា ................................ | ២៩៣ |
| ហ្វូងនិពទ្ធមន្ត្រី ញ៉ុក - ថែម | គន្លឹះអាស៊ីទ្វីប (តមក)................... | ៣០៦ |
| **កំណត់ទិនប្រវត្តិការណ៍** | | |
| ភិក្ខុ សួន - ស៊ីន | បុណ្យឈាបនកិច្ចសពអ្នកអាចារ្យ ហ៊ុន - សុធិ . | ៣១២ |
| ក្រសួងធម្មការ | អំពីការតាំងចៅអធិការថ្មី (តមក) .......... | ៣... |


ឆ្នាំទី ២១ — លេខ ៤ ខែមេសា ឆ្នាំ ១៩៤៩ — ថ្លៃជាវ ១ ឆ្នាំ ៩៦ រៀល ។

# សាមគ្គីកថា

ជាទេសនាកថា របស់ព្រះមេគណព្រះមហា រស់-កោ (កោវិទត្ថេរ)

អាចារ្យបង្រៀនសាលាបាលីរង វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តអរហំសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយគោរព ។

លំដាប់នេះ ខ្ញុំនឹងសំដែងអំពីដំណើរនៃសន្តិសុខក្នុងលោក ដោយសង្ខេបតាមកាលវេលាដូចតទៅនេះ ។

សុខា សង្ឃស្ស សាមគ្គី «សេចក្ដីព្រមព្រៀងគ្នារបស់ពួកក្រុមនាំឲ្យកើតសន្តិសុខ (ក្នុងលោក)» ។

ពុទ្ធភាសិតនេះ មានសេចក្ដីដែលត្រូវតែស្រង់យកមកប្រែ និងអធិប្បាយ ៣ បទ គឺ: សាមគ្គី ១ បទ, សង្ឃ ១ បទ, សុខ ១ បទ ។

សាមគ្គី ប្រែថា «សេចក្ដីព្រមព្រៀងគ្នា, ដំណើរស្រុះស្រួលមូលមិត្រនឹងគ្នា, រួបរួមគ្នា, ចងបាច់គ្នា, ត្រូវរ៉ូវគ្នា, ពេញចិត្តគ្នា, មានចិត្តស្មើគ្នា, មានអធ្យាស្រ័យត្រូវគ្នា, ចុះចិត្តគ្នា, មិនបែកចិត្តពីគ្នា, មានចិត្តស្មោះស្ម័គ្រដូចគ្នា, មានករណីយកិច្ចត្រូវគ្នា, ចុះចិត្តពិតដូចគ្នា, ចុះសំរុងគ្នា, មានមេត្រីចិត្តរលាយចូលគ្នាដូចទឹកនឹងទឹក ឥតទាស់ទែងនឹងគំនិតគ្នា, មិនប្រកួតប្រជែង, មិនចងគំនុំ» ។

សង្ឃៈ ប្រែថា «ពួក, ក្រុម, ប្រជុំ, ហ្វូង, បន, គុត, គណៈ, និកាយ, សង្គម, បរិស័ទ» ៗ តែបើតាមព្រះវិន័យ សំដៅយកបព្វ-ជិតតាំងពី ៤ រូបឡើងទៅ ។

សុខៈ ប្រែថា «សេចក្ដីសប្បាយ» ធម្មជាតនេះសោះ តែជារបស់គួរស្រឡាញ់, ដំណើរស្រួល, រីករាយ, ស្រណុក, មិនក្រវល់ក្រវាយ, មិនរំគរ, មិនជ្រួលច្របល់, មិនកាំចិត្ត, មិនក្ដៅក្រហាយ, មិនស្ដាយក្រោយ សេចក្ដីសម្រាន្ត» ៗ តែក្នុងទីនេះ សំដៅយកសន្តិសុខ គឺសេចក្ដីសុខ ស្ងប់ ឬសន្តិភាព ដែលជាទីប្រាថ្នា របស់លោកទាំងមូល ។

កាលបើរួមសេចក្ដីប្រែនៃពុទ្ធភាសិតទាំង ៣ បទនេះ ទៅជាប្រយោគ ១ ទៅ នឹងឃើញបានយ៉ាងច្បាស់ថា សាមគ្គីជាសុខហេតុ គឺថា បើសាមគ្គីរបស់ពួកក្រុមកើតមានឡើងហើយ សន្តិសុខជាទីស្រឡាញ់ ក៏នឹងកើតឡើងយ៉ាងងាយ ដោយមិនបាច់វិនិច្ឆ័យរកផ្លូវដទៃក្រៅពីនេះឡើយ ។

សាមគ្គីនេះ ចែកចេញជា ៣ យ៉ាងគឺ កាយសាមគ្គី «សេចក្ដីព្រមព្រៀងគ្នា ដោយកាយ» ១, វចីសាមគ្គី «សេចក្ដីព្រមព្រៀងគ្នាដោយសំដី» ១, ចិត្តសាមគ្គី «សេចក្ដីព្រមព្រៀងគ្នាតាមផ្លូវចិត្ត» ១, ។

ការស្រុះស្រួលគ្នាទៅវិញទៅមក រវាងពួកគណឬសង្គម រហូតដល់លោកជាទីបំផុត មិនប្រកាន់ចែកគ្នាជាពួកបក្ស រមែងជាបច្ច័យ

ឲ្យបានទទួលសន្តិសុខ និងសេចក្ដីចំរើនរុងរឿងឥតអាក់ ឥតមានឧបសគ្គអ្វីមករាំងរាកបានឡើយ ។ សាមគ្គីនេះ ទុកជាទីពឹងមាំមួយយ៉ាងសំខាន់ ដែលអាចជួយសាសនា, ប្រទេសជាតិ, និងលោកទាំងមូល ឲ្យបានចំរើនជាប់ជាស្ថិតស្ថេរ មិនឲ្យត្រឡប់ទៅវិញឡើយ ឬវិនាសទៅបាន ។ បើសាសនិកជន ឬប្រទេសជាតិណា មានសាមគ្គីផុះផុលទាំងនៅជាប់មាំល្អ សាសនិកជន ឬប្រទេសជាតិនោះ នឹងបានសេចក្ដីសុខចំរើនយ៉ាងអស្ចារ្យ ឥតមានអំណាចអ្វីទៅលុកលុយ ឲ្យសាបសូន្យរលាយរលត់បានឡើយ ប្រៀបដូចជាសរសៃអម្បោះតូចៗ តែគេយកច្រើនសរសៃវេញត្របាញ់ចូលទៅជាមួយគ្នា គេអាចយកអម្បោះនោះទៅចងដំរីជាដើម ដែលជាសត្វធំមានកម្លាំងច្រើនឲ្យជាប់បាន សត្វនោះមិនអាចទាញរើ ឲ្យដាច់ខ្សែអម្បោះនោះបានឡើយ ។ សម្បូររូបកាយយើងនេះ ដែលនឹងតាំងនៅ ឬចំរើនឡើងបាន ក៏ដោយអាស្រ័យសាមគ្គីរបស់ធាតុ ៤, អាការៈ ៣២ និងសរសៃពួរៈផ្សេងៗផង; បើរបស់ទាំងនេះមិនរួបរួមគ្នា មិនហុចឬមិនបែងចែកកំឡាំងផល់គ្នានិងគ្នាហើយ រូបកាយយើងក៏លែងប្រព្រឹត្តទៅបាន ។

នៅក្នុងព្រៃ សត្វចតុប្បាទមាឌតូចៗមួយពួក ហៅថា ឆ្កែព្រៃ មាឌតូចជាងឆ្កែស្រុកទៅទៀត តែវាមានសាមគ្គីស្រុះគ្នាជាបំផុត វាអាចតាមកេមទាំងខ្លាឬសីហៈ ដែលជាសត្វមានមាឌសម្បើមហើយកាចសា-

ហាក់យ៉ាងនេះក្រៃលែងនិយមជាសាហាវក៏បាន ខ្លាំងនឹងសីហៈ តែនៅមានមហា-ភ័យដ៏ពន្លឺស៊ីពីក្តៅព្រៃជានិច្ច ។

ស្រះចាប, សង្ហារ, ធរណៀរ, ឃុំនឹងព្រៃមាឃជាដើម អាស្រ័យការសាមគ្គីស្រុះគ្នា អាចធ្វើកិច្ចរបស់ខ្លួន ឲ្យសម្រេចតាមបំណងគ្រប់ផ្លូវបាន ទាំងនេះក៏ព្រោះសាមគ្គីជាហេតុ ។

ក្តៅព្រៃជាដើម ជាសត្វតិរច្ឆានមានអាយុខ្ទូបតាប ឥតដែលមានសាសនាប្រដៅ ឥតដែលមានសៀវភៅក្បួនច្បាប់សម្រាប់មើល ទាំងគ្មានអ្នកប្រាជ្ញណាប្រដៅឲ្យចេះស្រឡាញ់រាប់អានគ្នា ឲ្យមានសាមគ្គីស្រុះគ្នាសោះ ក៏ចេះបណ្តុះសាមគ្គីក៏នឹងគ្នាក៏បាន ។ ចុះយើងជាមនុស្សជាតិត្រឡាំងៗ, មានសាសនាល្អសម្រាប់កាន់, មានសៀវភៅក្បួនច្បាប់សម្រាប់មើល, មានអ្នកប្រាជ្ញរៀនប្រដៅ, ទាំងមានជាតិជាអ្នកដឹងខុសត្រូវស្រាប់ ម៉េចក៏ទៅជាបណ្តុះសាមគ្គីមិនកើត? អ្នកដែលមិនគោរពសាសនាទៅចុះ យើងមិនបាច់និយាយដល់; ចុះប្រជាជនជាតិខ្មែរយើងដែលកាន់ព្រះពុទ្ធសាសនាទាំងស្រុង ម៉េចក៏មិនគិតដល់ពុទ្ធភាសិតត្រង់នេះផងនោះ? ម្តេចក៏បណ្តោយឲ្យបែកសាមគ្គី ទៅជាពួកបក្ស គណៈនិកាយផ្សេងៗ? គួរឬ? បើដូច្នេះតើ នឹងឲ្យព្រះពុទ្ធសាសនា ចំរើនរុងរឿងដូចម្តេចបាន? ការទំប្រើងនេះព្រោះនៃព្រះពុទ្ធសាសនា នឹងប្រទេសជាតិឲ្យគង់ចំរើន ដោយប្រាសចាកឧបាយ រួបរួមបណ្តុះសាមគ្គីជាការឥតអំពើ

ទុកដូចជាគេមកដំរីខ្លាប់ទៅស្ទូចគ្រាញ់មកប្រើ រមែងប៉ះប្រទះនឹងឲ្យបសុសត្វនាំឲ្យលំបាកជាអនេក ហើយថែមទាំងឥតបានសម្រេចប្រយោជន៍អ្វីឡើយ ។

ក្នុងសម័យឥឡូវ ដំណើរនៃសីលធម៌នឹងសាមគ្គីធម៌លេចខ្សត់ខ្សោយអស់ទៅ នាំឲ្យអស់សង្ឃឹម ក្នុងសន្តិសុខព្រមទាំងវឌ្ឍនធម៌ បើទុកជាចំរើនប្រែប្រួលទៅដោយសតិបញ្ញាដ៏ល្អិតសុខុមយ៉ាងណា ក៏នៅតែកម្រនឹងធ្វើ ឲ្យកើតឲ្យចំរើនឡើងបាន ។

តាំងពីយូរយារណាស់មកហើយ មកដល់សព្វថ្ងៃ លោកទាំងអស់គំពូងប្រឹងប្រែងរកឧបាយបង្កើតឲ្យមានសន្តិសុខ រហូតដល់ទៅបង្កើតឲ្យមានវេទិកាសន្តិសុខសម្រាប់លោក ដែលហៅថា អង្គការសហប្រជាជាតិ; ប៉ុន្តែមកទល់នឹងថ្ងៃនេះ ស្ទើរតែមិនបានជួបប្រទះនឹងស្រមោលនៃសន្តិសុខសោះ ។ មិនមែនដោយការបង្កើតគ្រឿងការពារយុទ្ធភណ្ឌស្ទូកស្ទះលោកនេះទេ ដែលនឹងនាំយកមកប្រើបង្កើតជាថែបសន្តិសុខនោះ ។ បើលោកទាំងមូលនៅតែសង្ឃឹមលើកម្លាំងកងទ័ព ដែលមានសព្វាវុធយុទ្ធភណ្ឌយ៉ាងសម្បើមដូច្នោះ នានាជាតិអស់នោះ នឹងមិនផុតពីសេចក្តីក្តៅក្រហាយដែលមករួបរឹតខ្លួនឯងឡើយ ។

បើតាមច្បាប់ពុទ្ធសាសនាយើងសំដែងថា សន្តិសុខក្នុងលោកនេះនឹងកើតមានឡើង ក៏ដោយសារកំលាំងនៃសាមគ្គីធម៌នឹងមេត្រីចិត្ត

ដំបាំសុខដំមានរបៀបបែបផែន ទាំងមនុស្សម្នាក់ៗ និងមនុស្សទូទៅ តែចំពោះក្រៅពីនេះមិនមាននោះឡើយ ។ បើពិចារណាឲ្យជ្រៅល្អិតល្អទៅ គួរជឿយកជាការពិតបានណាស់ ។

ឯការប្រែជា បាត់បែង ខូចខាតឥទ្ធិពលនៃសាមគ្គីធម៌នេះ កើតឡើងដោយសារហេតុច្រើនប្រការគឺ ដោយសារឧបក្កិលេស, ដោយសារអគតិ និងដោយសារទិដ្ឋិជាដើម ។ ហេតុទីមួយបានដល់

## ឧបក្កិលេស ១៦ គឺៈ

១– អភិជ្ឈាវិសមលោភៈ សេចក្តីលោភចង់បានហួសទំនងឬ បំពានលើលោភយករបស់គេ ។

២– ទោសៈ ប្រទូស្ត ឬបៀតបៀនជិះជាន់គេទាំងអំណាច

៣– កោធៈ ក្រោធខឹង ឬធ្វើទុក្ខបុកម្នេញគេ

៤– ឧបនាហៈ ចងក្រោធទុក ឬចងគំនុំ

៥– មក្ខៈ លុបគុណ ឬរំលើគុណគេ

៦– បលាសៈ ការយកខ្លួនស្មើ លើកខ្លួន ឬប្រណាំងការសមា

៧– ឥស្សា ច្រណែនឈ្នានីសគេ មិនចង់ឲ្យគេមានបាន

៨– មច្ឆរិយៈ កំណាញ់ស្វិតស្វាញ មិនព្រមចែករំលែកលាភ-យស-សុខសរសើរ ឬប្រយោជន៍ព្រមទាំងគុណភាពនិងសមត្ថភាពដល់គេ

៩- មាយា មានពុតត្បុតការក្រក់ ឬបិទបាំងទោសខ្លួន ទំលាក់ទោសទៅលើអ្នកដទៃ ។

១០- សាឋេយ្យៈ អួតអាង ឬអែបអបបំខ្លួន

១១- ថម្ភៈ កោងឆមព្រហើន ឬ ចចេសមុខរឹង

១២- សារម្ភៈ អួតថាខ្លាំង ឬ ដណ្តើមខ្លាំងលើគេតែឯង

១៣- មានះ កាន់ខ្លួន ឆ្មើងកន្ទ្រើង ឬ ក្រអឺតក្រអោង

១៤- អតិមានះ មើលងាយគេ ឬ មាក់ងាយមាក់ងោគេ

១៥- មទះ ស្រវឹងឈ្លក់ក្នុងលាភ-យស-សុខ-សរសើរ

១៦- បមាទះ ធ្វេសប្រហែស លង់ខ្លួន ភ្លេចស្មារតី ឬប្រាស សតិសម្បជញ្ញៈ ។

ឯហេតុទីពីរបានដល់

## អគតិ ៤ គឺៈ

១- ឆន្ទាគតិ សេចក្តីលំអៀង ឬ យល់មុខព្រោះស្រឡាញ់, ព្រោះគាប់ចិត្ត ។

២- ទោសាគតិ សេចក្តីលំអៀងឬ ផ្តួលព្រោះស្អប់, ព្រោះខឹង ។

៣- មោហាគតិ សេចក្តីលំអៀងឬ ខុសគុណព្រោះល្ងង់, ព្រោះពុំយល់ការខុសត្រូវ ។

៤ – ភយាគតិ សេចក្ដីលំអៀង ឬ រណោបរណើបផែបតបព្រោះ ខ្លាចបុណ្យខ្លាចអំណាច ឬ ខ្លាចចិត្តគេ ។

ចំណែកខាងហេតុនាំឲ្យបានផល

## ទិដ្ឋិ ឬ សត្រូវធំ ២ គឺៈ

១ - ឧច្ឆេទទិដ្ឋិ លទ្ធិមិនជឿស្ថានសួគ៌-នរក មិនជឿបុណ្យ បាប គិតតែឲ្យបានច្រើន បានសប្បាយក្នុងបច្ចុប្បន្ន

២ អត្តទិដ្ឋិ លទ្ធិគិតតែប្រយោជន៍ខ្លួន ពួកគណៈខ្លួន ជាតិខ្លួន មិនគិតដល់ជាតិគេផង ។

ធម៌ណាមកប៉ុណ្ណោះជាដើម សុទ្ធតែជាធ្នូបំបែកសាមគ្គី ជាមេបំផ្លាញសាមគ្គី ឲ្យអន្តរាយសាបសូន្យទៅ ។ ហេតុនេះ នាយករបស់សាសនា ឬនាយករបស់រដ្ឋទាំងឡាយ ត្រូវតែជៀសវាងឲ្យស្រឡះ កុំបណ្ដោយឲ្យកើតមានក្នុងខ្លួន ទើបការបណ្ដុះសាមគ្គីរវាងសាសនិកជន ឬមនុស្សជាតិផងគ្នាឲ្យកើតបាន ។

ព្រោះនេះ ខ្ញុំស្រាវជ្រាវរកធម៌សម្រាប់បណ្ដុះសាមគ្គី ដែលធម៌ជាគ្រឿងធ្វើសាមគ្គីឲ្យល្អលាស់ ចំរើនឡើង ។ ទើបកើតប្រស្នាថាៈ ធម៌-អ្វីខ្លះជាគ្រឿងបណ្ដុះសាមគ្គី? សាមគ្គីនឹងល្អលាស់ចំរើនឡើងដោយសារធម៌អ្វី? ខ្ញុំសូមដោះស្រាយប្រស្នាទាំងនេះ តាមច្បាប់ព្រះពុទ្ធសាសនា

យើងតែម្យ៉ាង បើនឹងគេផ្សេងទៀតមកប្រកបផងក៏បាន តែនឹងនាំឲ្យយឺតយូរ ហួសពេលវេលា ។

សាមគ្គីនឹងកើតឡើងបាន ឬសូម្បីប្រេះឆាហើយ ក៏នឹងផ្សារគេ ឲ្យជាប់វិញបាន ដោយអាស្រ័យធម៌ច្រើនប្រការគឺ ៖ ដោយសារ សង្គហវត្ថុនិងសារាណីយធម៌ជាដើម ។

## សង្គហវត្ថុមាន ៤ គឺ ៖

១– ទានៈ ការឲ្យទេយ្យវត្ថុ ឬរំលែកអាហារនិងសម្ភារៈឲ្យ ដល់គ្នានឹងគ្នាតាមការគួរ ។

២ បេយ្យវជ្ជៈ ការពោលពាក្យឲ្យចង់ឮចង់ស្ដាប់ ឬទុសព្រហ៍ កក់ក្ដៅដោយពាក្យពីរោះចំពោះជនទូទៅមិនរើសមុខ ទីនឹងស្រាហ៍រលីក ជាសំនៀងប្រាប់ប្រយោជន៍, ច្បាប់ទំលាប់និងសេចក្ដីខុសត្រូវ ។

៣ - អត្ថចរិយា ការប្រព្រឹត្តិធ្វើជាប្រយោជន៍ដល់គ្នានឹងគ្នា ឬធ្វើប្រយោជន៍ឲ្យកើតឡើងដល់ខ្លួនព្រមទាំងអ្នកដទៃ ។

៤ – សមានត្តតា ការតាំងខ្លួនស្មើៗ មិនរើសថ្នូរ មិនប្រកាន់ខ្លួនដោយជាតិ, ត្រកូល, យសស័ក្តិ, ទ្រព្យសម្បត្តិ ។

## សារាណីយធម៌មាន ៦ គឺ ៖

១ - មេត្តាកាយកម្ម ការងារដែលត្រូវធ្វើតាមផ្លូវកាយ សុទ្ធតែប្រកបដោយមេត្តា ឬមេត្រីចិត្តដល់គ្នានឹងគ្នា ។

២ - មេត្តាវចីកម្ម កិច្ចការដែលត្រូវចាត់ចែងដោយសំដី សុទ្ធតែប្រកបដោយមេត្តា ។

៣ - មេត្តាមនោកម្ម អំពើដែលគិតទុកក្នុងចិត្ត សុទ្ធតែប្រកបដោយមេត្តា ឬមេត្រី ។

៤ - លាភ: ការចែករំលែកលាភ - យស - សរសើរ នឹងសុខដល់គ្នា ។

៥ - សីល: ដំណើរមានសណ្តាប់ធ្នាប់, របៀបរៀបរយ នឹងសេចក្តីប្រព្រឹត្តត្រូវគ្នា តែបែបមួយ ។

៦ - ទិដ្ឋិ សេចក្តីយល់ឃើញត្រូវគ្នា ចុះសំរុងគ្នា ឬលទ្ធិត្រូវគ្នា មិនខុសស្ទាគ្នា ។

ធម៌ដ៏ឧត្តមប៉ុណ្ណោះជាដើម សុទ្ធតែជាមេ ឬជាបច្ច័យឲ្យកើតសាមគ្គី ទាំងជាគ្រឿងផ្សារសាមគ្គីដែលប្រេះឆាហើយ ឲ្យជាប់មាំវិញបាន ។ គួរបុគ្គលជានាយកទាំងឡាយ ព្រមទាំងសាសនិកជន នឹងប្រជាជនទូទៅ បណ្តុះឲ្យមានក្នុងខ្លួន ទើបពេញលក្ខណៈជាមហាបុរស ជាវរបុរស ឬជាបរិសទ្យ ជាពលរដ្ឋពិតៗ ដែលនាំឲ្យបានសុខចំរើន ។

សាមគ្គីធម៌ ដែលនឹងមានអាយុជីវិតលូតលាស់ចំរើនឡើងបាន ក៏ព្រោះអាស្រ័យធម៌ ៦ យ៉ាងទៀត គឺ

១ - វិរិយៈ សេចក្ដីព្យាយាមក្លៀវក្លា ។

២ - ខន្តិ សេចក្ដីអត់ធន់ ឬការស៊ូអត់ធ្មត់ចំពោះការងារ ។

៣ - សច្ចៈ សេចក្ដីពិតស្មោះត្រង់ដល់គ្នានឹងគ្នាមិនក្បត់ចិត្តគ្នា ។

៤ - អធិដ្ឋានៈ សេចក្ដីដាក់ខ្លួនដោយឧបាយបញ្ញា ។

៥ - មេត្តា សេចក្ដីរាប់អានគ្នាដោយស្និទ្ធស្នាល ។

៦ - បរិច្ចាគៈ ការចែករំលែកដោយសង្គ្រោះ ឬដោយការបូជាគុណ ។

ធម៌ទាំង ៦ យ៉ាងនេះ ទុកដូចជាអាហារចំណីសម្រាប់ចិញ្ចឹមសាមគ្គីឲ្យរីកធាត់ធំមាំមួន ទាំងនោះទុកដូចជាជីជាតិសម្រាប់ស្រោចស្រពប្រែសព្រៃសាមគ្គី ដែលធ្វើឲ្យដុះដាលលូតលាស់ចំរើនឡើង ។ ឯសាមគ្គីនោះ បើប្រាសចាកធម៌ទាំងនេះហើយ គង់តែនឹងរលត់រលាយស្វិតស្រពោនទៅ ឬក៏តែងបាក់រលាយបាក់ទៅ ដោយឆាប់រហ័សពុំខាន ។

ព្រោះហេតុនោះ សាធុជនអ្នកមានបំណងល្អចំពោះសាសនា, ចំពោះប្រទេសជាតិរបស់ខ្លួន ឬចំពោះលោកទាំងមូល ចង់ឲ្យបានសន្តិសុខចំរើនរុងរឿង ត្រូវតែដំកល់ខ្លួនឲ្យតាំងនៅក្នុងគុណធម៌ទាំងអស់ ដូចរៀបរាប់មកជាសង្ខេបប៉ុណ្ណេះ ធ្វើសាមគ្គីធម៌ — សីលធម៌ — វប្បធម៌ - យុត្តិធម៌ឲ្យដុះដាលលូតលាស់ឡើងវិញ ហើយឲ្យចំរើនរុងរឿងតទៅ ។

ស្ទូវជ្រាបរជាមខ្ញុំថា ព្រះពុទ្ធសាសនាដែលផុតរលត់បាត់បង់ពី (ប្រទេសឥណ្ឌា) ក៏ព្រោះតែពុទ្ធបរិស័ទបែកសាមគ្គី ទៅជាគណៈនិកាយ យ៉ាំងច្រើនដល់ទៅកាំ ៨០ និកាយ ប្រទេសដ៏ទៃក្នុងពុទ្ធសម័យ មាន របៀបគិតត្រឹមថា ហាតាណាផ្ទុយ ហៅថា ពុទ្ធដីកា សម័យបុរាណ កាប្រើយ ហាមគ្គីនិមិត្តហេតុ ទើបក្រុមស្រា ប៉ុន្តែ ហិតផលានិសង្ស នោះ នៅក្រុមខ្មែរប្រាំបីចំពុះ ពាប់តែព្រះពុទ្ធជាម្ចាស់ទ្រង់ប្រដូចនៅ នឹងសាធុស្តិ ឈ្មោះពាទុកហាកផិកា ចាំង៉ទ្រង់ព្យាករណ៍ថា បើសិនដែល វង្វេងនៅតែមានសាមគ្គីប្រព្រឹត្តតាមសប្បាយជាធម៌ដូច្នេះ ដែនវង្វេងនោះនឹង បរិវត្តន៍រឿងឥតកាក់ ឥតមានព្រះទេសណាទៅលុតបុរយបានឡើយ ។ តែសម័យឥឡូវ អ្នកដែលប្លែងបែកសាមគ្គីគ្នា ទៅជាពុកជាគណៈ បៀក បៀនគាប់សម្លាប់តែគ្នាឯង មិនយូរប៉ុន្មានក៏ត្រូវអ្នកដែលសហជីពមកផ្ទះ លើកគំនិតពាក្យលក់ខ្លួន ពាល់តែលោ ចរលត់បាត់ឈ្មោះពីដែនដី លោកហូតដល់សព្វថ្ងៃ នេះព្រោះតោលបំបែកសាមគ្គី ។

បើតាមផ្លូវធម៌វិញ សូម្បីអរិយមគ្គប្រកបដោយអង្គ ៨ ដែលជា ធម៌ជាទីពឹង ក៏ប្រើតែគ្រឿងគ្នាក់សាមគ្គី ទើបកាត់កាត់ផ្តាច់កិលេសបាន ឥតមានអរិយមគ្គណាមួយ កាត់ចេញមុនពាល់គ្នាឯង ទៅកាត់ផ្តាច់ ប្រហារកិលេសបានឡើយ ។

ព្រោះហេតុដូចបរិយាយមកនេះ ទើបគួរតែនាំគ្នាប្រមូលសាមគ្គីឡើង រាប់អានផងជាតិតែមួយគ្នា ឬអ្នកកាន់សាសនាជាមួយគ្នា ហេតុដល់លោកទាំងមូលដែលជាមនុស្សជាតិដូចគ្នា ទើបសេចក្ដីសុខសេចក្ដីចំរើនដែលជាកំពូលនៃសេចក្ដីប្រាថ្នា នឹងកើតមានឡើងយ៉ាងពិតប្រាកដពុំខាន ។

សូមអស់លោក-អ្នកស្ដាប់បានឮ ចំណាំចាំទុកហើយប្រតិបត្តិយកប្រយោជន៍តាមគួរដល់អធ្យាស្រ័យចុះ ។ សំដែងមកក្នុងសាមគ្គីកថាចប់តាមកាលវេលាតែប៉ុណ្ណេះ ។

សូមសុខសួស្ដីសិរីវុឌ្ឍិភាព កើតមានដល់លោកអ្នកស្ដាប់ អស់កាលជាអង្វែងទៅហោង ។

ព្រះមហា រស់-គា ( កៅខាក្មេរ )